**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម Martin Vávra ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋឆែក ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

* * * * * *

នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតជូន ឯកឧត្តម ម៉ាទីន វ៉ាវ៉ា (**Martin Vávra**) ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពថ្មីនៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១នេះ គឺជាខួបលើកទី៦៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឆែក ហើយរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរបានផ្លាស់ប្តូរសារអបអរសាទរ និងជូនពរគ្នាទៅវិញទៅមកក្នុងឱកាសដ៏ប្រសើរនេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** សូមអរគុណរដ្ឋាភិបាលឆែក ដែលបានរក្សាទុកប្រទេសកម្ពុជាក្នុងចង្កោមប្រទេសអាទិភាពចំនួន៦ សម្រាប់ជាដៃគូអភិវឌ្ឍន៍។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ ជាពិសេស ការយាងបំពេញទស្សនកិច្ចផ្លូវរដ្ឋរបស់ **ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាអម្ចាស់ កាលពីខែកញ្ញា ឆ្នាំ២០០៦ និង ទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីខែតុលា ឆ្នាំ២០១៩ នៅសាធារណរដ្ឋឆែក បានជួយពង្រឹងបន្ថែមទៀតនូវចំណងទាក់ទងរវាងប្រទេសទាំងពីរ ព្រមទាំងបានជួយបង្កើតសក្តានុពលភាពជាច្រើនសម្រាប់កិច្ចសហប្រតិបត្តិការដែលមានផលប្រយោជន៍ទៅវិញទៅមក។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានមានប្រសាសន៍ថា ឯកឧត្តមមានសេចក្តីសោមនស្សរីករាយ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតឆែកប្រចាំកម្ពុជា ហើយ**ឯកឧត្តម**ប្តេជ្ញាចិត្តខិតខំពង្រឹងនិងពង្រីកបន្ថែមទៀតនូវទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យឈានឡើងខ្ពស់មួយកម្រិតថែមទៀត និងធ្វើឱ្យកិច្ចសហប្រតិបត្តិការនៅលើវិស័យសំខាន់ៗបានប្រកបដោយផ្លែផ្កា។ ឯកឧត្តម ក៏មានការជឿជាក់ថា នៅក្នុងអាណត្តិរបស់ឯកឧត្តម ក្រោយវិបត្តកូវីដ-១៩ នឹងមានទស្សនកិច្ចទ្វេភាគីរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។ **ឯកឧត្តម** ក៏បានជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ថា ឯកឧត្តមបានធ្វើដំណើរ



ᘓ.

ទៅខេត្តមួយចំនួនរបស់កម្ពុជា រួមមានខេត្តបាត់ដំបង ដើម្បីពិនិត្យមើលសក្តានុពលភាពពាណិជ្ជកម្ម ជាពិសេសផ្នែកកសិកម្មកែច្នៃ។

**ភាគីទាំងពីរ**បានយល់ស្របគ្នាថា កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ គឺជាយន្តការមានសារៈសំខាន់ និងជួយរួមចំណែកដល់ការពង្រឹង និងពង្រីកទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការនៅលើវិស័យជាច្រើន។ កិច្ចប្រជុំនេះត្រូវបានរៀបចំលើកទី១ នៅប្រទេសឆែក នៅថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយនឹងត្រូវរៀបចំលើកទី២ នៅកម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩។

**ភាគីទាំងពីរ**បានកត់សម្គាល់អំពីកំណើនជាលំដាប់នៃកិច្ចសហប្រតិបត្តិការទ្វេភាគី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ប្រទេសឆែកដែលបានផ្តល់អាហារូបករណ៍ជាច្រើនដល់សិស្ស-និស្សិតកម្ពុជា នាពេលកន្លងមក ហើយដែលនៅក្នុងឆ្នាំសិក្សា២០២១-២០២២ ប្រទេសឆែកបានផ្តល់អាហារូបករណ៍សម្រាប់ថ្នាក់ក្រោយឧត្តមសិក្សាជាភាសាអង់គ្លេសចំនួន ១៧កន្លែង ដល់និស្សិតកម្ពុជា។

**ភាគីទាំងពីរ**បានឯកភាពគ្នាធ្វើកិច្ចសហការនិងពិគ្រោះយោបល់គ្នាយ៉ាងជិតស្និទ្ធ ក្នុងក្របខ័ណ្ឌអាស៊ាន នៅពេលដែលប្រទេសឆែកទទួលធ្វើជាប្រធានសហភាពអឺរ៉ុបក្នុងឆមាសទីពីរនៃឆ្នាំក្រោយ ស្របពេលដែលប្រទេសកម្ពុជា ទទួលធ្វើជាប្រធានអាស៊ាន។

នៅចុងបញ្ចប់នៃជំនួប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្ត ឯកឧត្តមឯកអគ្គរដ្ឋទូតអញ្ជើញជួបដោយផ្ទាល់ជាមួយរដ្ឋមន្ត្រីតាមក្រសួងនានារបស់កម្ពុជា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយគ្នាមានផ្លែផ្កាថែមទៀត៕

--------------------